long beach unified school district

កម្មវិធីបង្ហាត់ BP 6020.1

**<u>ច្បាប់ទាក់ទងការរួមចំណែកពីមាតាបិតានៅតាមសាលារៀនទទួលជំនួយ Title I</u>**

គណៈកម្មាធិការចាត់ចែងកម្មវិធីសិក្សា ទទួលស្គាល់ថា មាតាបិតា/អ្នកគ្រប់គ្រងសិស្សមកពីដើមកំណើតចម្រុះទាំងអស់នៅក្នុងក្រសួងអប់រំ ឱស្រ្ទីគ គឺមានមុខងារផ្តល់ជំនួយដ៏សំខាន់អំពីផ្នែកអប់រំសិស្ស ។ គណៈកម្មាធិការមានជំនឿថា កម្មវិធីសិក្សានៃសិស្ស គឺជាមុខងារទទួលខុសត្រូវស្មើគ្នារវាងក្រុមគ្រួសារ និង សាលារៀន ។ ដើម្បីបញ្ជាក់អំពីការបង្រួបបង្រួមគ្នាដ៏ពិតប្រាកដ គឺគណៈកម្មាធិការ, នាយកសាលា និង បុគ្គលិកទូទៅ តាំងចិត្តបង្កើតជាកម្មវិធីសំរាប់មាតាបិតាចូលរួមចំណែក ដែលត្រឹមត្រូវតាមទំហំ និង គុណភាពនៃមុខនាទីសំរាប់បង្កើនទំនាក់ទំនងយ៉ាងសក្តិសិទ្ធរវាងផ្ទះ និង សាលារៀន តាមរយៈ ...

1. ទាក់ទាញមាតាបិតា/អ្នកគ្រប់គ្រងសិស្សចូលរួមចំណែកជាមួយការបង្កើតគម្រោងការណ៍ Title I ប្រចាំក្រសួងអប់រំ ឱស្រ្ទីគ ដែលមានជាកម្មវិធីច្រើនយ៉ាងសំរាប់បង្កើនគុណភាពផ្នែកសិក្សានៅក្នុងសាលារៀន រួមទាំងរាប់បញ្ចូលមាតាបិតាផង សំរាប់ជួយពិនិត្យសើរើ និង ស្វែងរកមធ្យោបាយកែតម្រូវ ។

2. ពិគ្រោះជាបន្តបន្ទាប់ជាមួយមាតាបិតា/អ្នកគ្រប់គ្រងសិស្សអំពីបញ្ហា ដែលសាលារៀន និង មាតាបិតា/អ្នកគ្រប់គ្រងសិស្សអាចបំពេញកិច្ចការរួមគ្នាបាន ដើម្បីស្វែងរកគោលដៅ, រៀបចំគម្រោងការណ៍, បង្កើត, ប្រព្រឹត្តតាម និង ស្ទង់មើលឡើងវិញអំពីកម្មវិធីនៅតាមសាលារៀន សំរាប់បញ្ជាក់ត្រឹមត្រូវអំពីភាពលូតលាស់ផ្នែកសិក្សានៃសិស្ស និង ការបង្ហាត់កម្មវិធីនៅក្នុងសាលារៀន ។

3. ផ្តល់កម្មវិធីសម្របសម្រួល និង ជំនួយទូទៅចាំបាច់ ដើម្បីជួយសាលារៀនអំពីរបៀបរៀបចំគម្រោងការណ៍ និង ការប្រព្រឹត្តតាមយ៉ាងសក្តិសិទ្ធជាមួយកិច្ចការទាក់ទងមាតាបិតា/អ្នកគ្រប់គ្រងសិស្ស ដើម្បីបង្កើនភាពលូតលាស់ផ្នែកសិក្សានៃសិស្ស និង ការបង្ហាត់កម្មវិធីនៅក្នុងសាលារៀន ។ យ៉ាងហោចណាស់ចំនួន 1% នៃថវិការ Title I, Part A ប្រចាំក្រសួងអប់រំ ឱស្រ្ទីគ នឹងត្រូវរក្សាទុកសំរាប់ប្រើលើកម្មវិធីសំរាប់មាតាបិតា ហើយ 95% នៃថវិការទាំងអស់នោះ នឹងចែកផ្តល់ទៅតាមសាលារៀនសំរាប់ប្រើលើកម្មវិធីផ្សេងៗ ដែលទាក់ទងការរួមចំណែកពីមាតាបិតា ។

4. គាំទ្រការប្រឹងប្រែងនៃមាតាបិតា/អ្នកគ្រប់គ្រងសិស្ស ដើម្បីជួយពួកគាត់ឲ្យយល់ និង ចេះធ្វើកិច្ចការជាមួយសិស្សអំពី ខ្នាតគំរូសិក្សា និង ការប្រឡង តែស្ត រដ្ឋ, ច្បាប់ចែងតម្រូវពី Title I, Part A និង របៀបតាមដានអំពីភាពលូតលាស់ផ្នែកសិក្សានៃសិស្សរបស់ពួកគាត់ និង កិច្ចការផ្សេងៗ ដែលត្រូវធ្វើជាមួយគ្រូបង្រៀន ដើម្បីបង្កើនផ្នែកបង្ហាត់មេរៀន ។

5. បង្កើនចំនួនមាតាបិតាកាន់តែច្រើនសំរាប់ទាក់ទាញពួកគាត់ចូលរួមជួយកិច្ចការមានប្រយោជន៍ និង ផ្តល់ឱកាសសំរាប់មាតាបិតា/អ្នកគ្រប់គ្រងសិស្សពង្រឹងចំណេះអប់រំ និង ចំណេះប្រើអក្សររបស់ពួកគាត់ ដើម្បីជួយមើលខុសត្រូវចំពោះការសិក្សានៃសិស្សនៅឯផ្ទះ ។

6. បញ្ជាក់ថា ពត៌មានទាក់ទងសាលារៀន និង កម្មវិធីសំរាប់មាតាបិតា, កម្មវិធីប្រជុំ និង កិច្ចការផ្សេងៗ ដែលផ្ញើទៅផ្ទះតាមរយៈក្រដាសស្នាម, សំបុត្រ និង សំណុំរឿង គឺពិតជាធ្វើត្រឹមត្រូវមែន ដោយសរសេរបង្ហាញជាភាសាកំណើត ដែលមាតាបិតាអាចយល់បាន, នៅពេលណាសាលារៀន ឬ ក្រសួងអប់រំ ឱស្រ្ទីគ មានចំនួនសិស្ស 15% ឬ លើសឡើងទៅ ដែលប្រើភាសាកំណើតផ្សេងនៅឯផ្ទះ ក្រៅពីភាសា អង់គ្លេស ។

7. បញ្ជាក់ប្រាប់មាតាបិតា/អ្នកគ្រប់គ្រងសិស្សអំពី (a) មូលហេតុ ដែលសិស្សរបស់ពួកគាត់កំពុងទទួលជំនួយនៅក្នុងកម្មវិធីណាមួយ, (b) គោលដៅច្បាស់លាស់នៃកម្មវិធីបង្ហាត់ និង មធ្យោបាយប្រើបង្ហាត់ និង (c) កម្មវិធីសិក្សាទូទៅនៃសិស្សរបស់ពួកគាត់នៅតាមសាលារៀន រួមទាំងមធ្យោបាយផ្សេងៗសំរាប់ពួកគាត់អាចជ្រើសរើសប្រើជាមួយបាន ដែលសមហេតុផលតាមសេចក្តីត្រូវការនៃសិស្សរបស់ពួកគាត់ ។

8. បង្ហាត់មាតាបិតា/អ្នកគ្រប់គ្រងសិស្ស និង គ្រូបង្រៀនឲ្យចេះធ្វើកិច្ចការរួមគ្នានៅឯផ្ទះ និង សាលារៀន ដើម្បីបង្កើនភាពលូតលាស់ផ្នែកសិក្សានៃសិស្ស និង ជម្រុញឲ្យមានទំនាក់ទំនងទៅវិញទៅមកយ៉ាងសក្តិសិទ្ធតាមរយៈប្រើភាសា ដែលមាតាបិតាទាំងអស់អាចយល់បាន និង ផ្តល់ជាកិច្ចសន្យារវាង សាលារៀន/ផ្ទះ ដែលបញ្ជាក់អំពីមុខងារទទួលខុសត្រូវស្មើគ្នារវាងបុគ្គលិកសាលារៀន, មាតាបិតា និង សិស្សក្នុងការបង្កើនភាពលូតលាស់ផ្នែកសិក្សាសំរាប់សិស្ស ។

9. លើកទឹកចិត្តមាតាបិតា/អ្នកគ្រប់គ្រងសិស្សឲ្យហ៊ានទទួលមុខងារដឹកនាំនៅក្នុងសាលារៀន និង នៅតាមក្រសួងអប់រំ ឪស្រ្ទីត អំពីផ្នែកចាត់ចែង, ផ្តល់ឱវាទ និង គិតគូរសម្រេច; ផ្តល់ឱកាសសំរាប់មាតាបិតាលើកបង្ហាញគោលគំនិតប្លែកៗទៅកាន់ក្រសួងអប់រំ ឪស្រ្ទីត បើសិនជាពួកគាត់មិនទទួលស្គាល់អំពីច្បាប់ទាក់ទងការរួមចំណែកពីមាតាបិតា និង គម្រោងការណ៍តែមួយសំរាប់កម្មវិធីសិក្សានៃសិស្សនៅតាមសាលារៀន ។

10. ផ្តល់កម្មវិធីហ្វឹកហ្វឺនសំរាប់គ្រូបង្រៀន, អ្នកផ្តល់ឱវាទ, នាយកសាលា និង បុគ្គលិកផ្សេងៗ, ក្រោមការជួយបង្ហាញគោលគំនិតពីមាតាបិតា, អំពីមធ្យោបាយទាក់ទង និង របៀបរៀបចំកម្មវិធីសំរាប់មាតាបិតា ដើម្បីបង្កើតជាដៃគូរវាងមាតាបិតា និង សាលារៀន ។

11. ទាក់ទាញមាតាបិតាចូលរួមចំណែកជាមួយការស្ទង់មើលឡើងវិញប្រចាំឆ្នាំអំពីខ្លាតគំរូសិក្សា, ភាពសក្តិសិទ្ធ និង អ្វីសំខាន់ផ្សេងៗទាក់ទងច្បាប់រួមចំណែកពីមាតាបិតាប្រចាំក្រសួងអប់រំ ឪស្រ្ទីត និង ច្បាប់រួមចំណែកពីមាតាបិតានៅតាមសាលារៀន ដើម្បីបង្កើនគុណភាពផ្នែកសិក្សានៅក្នុងសាលារៀន, រួមទាំងការស្វែងរកឧបសគ្គផ្សេងៗដែលនាំឲ្យរាំងស្ទះខ្លាំងមកលើកម្មវិធីសិក្សានៃសិស្ស ដោយប្រើតាមលទ្ធផលនៃការស្វែងរកឃើញ ដូចជាៈ ការស្ទង់មើលឡើងវិញ ដើម្បីរៀបចំមធ្យោបាយឲ្យកាន់តែសក្តិសិទ្ធសំរាប់ទាក់ទាញការរួមចំណែកពីមាតាបិតា និង ក្រុមគ្រួសារ ជាដើម ។

12. សម្របសម្រួល និង នាំបញ្ចូលកម្មវិធីរួមចំណែកផ្សេងៗសំរាប់មាតាបិតា ដែលមាននៅក្នុងក្រសួងអប់រំ ឪស្រ្ទីត ដូចជាៈ Child Development Centers (CDC), Head Start និង កម្មវិធី ព្រីស្គូល ឯទៀត ដើម្បីជម្រុញមាតាបិតាឲ្យចូលរួមចំណែកសំរាប់ជួយសិស្ស ព្រីស្គូល ។

13. សម្របសម្រួល និង តាមដានជាមួយមជ្ឈមណ្ឌលមាតាបិតា ដែលផ្តល់កម្មវិធីហ្វឹកហ្វឺនផ្នែករៀនអក្សរ, កិច្ចការសំរាប់ហាត់ធ្វើតាមនៅឯផ្ទះ និង ការអប់រំផ្សេងៗតាមសេចក្តីត្រូវការនៃមាតាបិតា ដើម្បីគាំទ្រផ្នែកសិក្សានៃសិស្សឲ្យបានប្រកបដោយជ័យ នៅពេលណាមានថវិការអាចប្រើជាមួយបាន ។

14. ជួយស្វែងរកជំនួយជូនមាតាបិតា/អ្នកគ្រប់គ្រងសិស្សនៅតាមក្រសួងអប់រំ ឪស្រ្ទីត និង ក្រសួងនានាៗនៅតាមសហគមន៍ ព្រមទាំងជំនួយគាំទ្រសមហេតុផលផ្សេងៗទៀតដែលមាតាបិតាបានស្នើសុំ ។

15. បង្កើតជា ក្រុមប្រឹក្សាផ្តល់ឱវាទសំរាប់មាតាបិតាប្រចាំក្រសួងអប់រំ ឪស្រ្ទីត (ឪខាក់) ដោយ … ជ្រើសរើសយកអ្នកតំណាងនៅតាមសាលារៀននិមួយៗ, ផ្តល់ឱវាទ ឬ គោលគំនិតផ្សេងៗទៅលើបញ្ហាទាក់ទងការរួមចំណែកពីមាតាបិតា, ជួយចាត់ចែងថវិការ Title I និង ឃ្លាំមើលអំពីកម្មវិធីផ្សេងៗ ដែលត្រូវបានយកថវិការមកប្រើប្រាស់ជាមួយ ។

ដកស្រង់ពីច្បាប់

EDUCATIONAL CODE
11500-11506 កម្មវិធីសំរាប់លើកទឹកចិត្តផ្នែករួមចំណែកពីមាតាបិតា
UNITED STATES CODE, TITLE 20
6301 គោលដៅនៃកម្មវិធី
6318 ការរួមចំណែកពីមាតាបិតា

| | |
|---|---|
| បានបង្កើតឡើងនៅៈ | ថ្ងៃទី28 ខែមករា ឆ្នាំ1991 |
| បានកែប្រែឡើងវិញនៅៈ | ថ្ងៃទី1 ខែមិនា ឆ្នាំ1994 |
| | ថ្ងៃទី6 ខែកុម្ភៈ ឆ្នាំ2001 |
| | ថ្ងៃទី7 ខែមិនា ឆ្នាំ2006 |
| | ថ្ងៃទី10 ខែវិច្ឆិកា ឆ្នាំ2007 |
| | ថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2010 |

LONG BEACH UNIFIED SCHOOL DISTRICT